# ការវិលត្រឡប់ទៅធ្វើការវិញដោយសុវត្ថិភាពសម្រាប់កម្មករ IUF ក្នុងអំឡុងពេលជំងឺកូវីដ-១៩

# ការទាមទារ៖ វិស័យសណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ និងម្ហូបអាហារ

កម្មករច្រើនលាននាក់នៅក្នុងវិស័យវិស័យសណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ និងម្ហូបអាហារកំពុងទទួលផលវិបាកដែលកើតចេញពីការរាតត្បាតនៃជំងឺកូវីដ-១៩។ ការបិទទ្វារអាជីវកម្មគ្រប់កន្លែងរបស់សណ្ឋាគារ បារនិងភោជនីយដ្ឋាន ក៏ដូចជាការដួលរលំជាទូទៅនៃវិស័យទេសចរណ៍ បានបង្កឲ្យមានមហន្តរាយសម្រាប់កម្មករ ដែលមានស្ត្រីច្រើនជាងពាក់កណ្ដាល។

នៅក្នុងប្រទេសមួយចំនួន រដ្ឋាភិបាលកំពុងបន្ធូរបន្ថយវិធានការរឹតត្បឹត ហើយនៅក្នុងរយៈពេលខ្លីមួយខាងមុខនេះ សណ្ឋាគារនិងភោជនីយដ្ឋាននានា នឹងបើកដំណើរការឡើងវិញ។ ខណៈពេលដែលការរឹតត្បឹតនិងវិធានការសុខភាព ដើម្បីធានាសុខភាពនិងសុវត្ថិភាពរបស់អតិថិជន មានសារៈសំខាន់បំផុតនោះ IUF មានការបារម្ភថា មានការយកចិត្តទុកដាក់មិនគ្រប់គ្រាន់ ពីនិយោជកនិងរដ្ឋាភិបាល ទៅលើសុខភាពនិងសុវត្ថិភាពរបស់កម្មករនៅក្នុងវិស័យសណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ និងម្ហូបអាហារ។

ទស្សនៈរបស់យើងគឺថា ដោយសារតែផលប៉ះពាល់ពីជំងឺរាតត្បាតនេះ ទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវសេដ្ឋកិច្ច និងដោសារតែការរៀបចំរចនាសម្ព័ន្ធឡើងវិញនៃវិស័យនេះ ពេលខ្លះដោយសារការចាំបាច់ និងពេលខ្លះទៀត ដោយសារតែឱកាស វានឹងត្រូវចំណាយពេលច្រើនឆ្នាំ ដើម្បីវិលត្រឡប់ទៅកម្រិតនៃសកម្មភាពមុនពេលកើតឡើងនៃជំងឺកូវីដ-១៩នេះ។ ចំណុចសំខាន់ក្នុងការកសាងវិស័យនេះឡើងវិញ ត្រូវការសម្លេងសហជីពដ៏រឹងមាំ ដែលជាមគ្គុទេសក៏ក្នុងការរៀបចំបង្កើតគោលនយោបាយ និងការអនុវត្តគោលនយោបាយ ក្នុងគោលបំណងដើម្បីធានាឲ្យមានវិធានការសុខភាពនិងសុវត្ថិភាពដ៏រឹងមាំ សន្តិសុខប្រាក់ចំណូល សន្តិសុខការងារ សមភាពយេនឌ័រ ដោយរួមបញ្ចូលទាំងការថែទាំសុខភាពនិងការសម្រាកពេលឈឺ និងសំខាន់បំផុតនោះ គឺសិទ្ធិសហជីព។

យើងបានកំណត់រកឃើញ វិស័យគន្លឹះសំខាន់ចំនួនបី ដែលត្រូវរៀបចំបង្កើតយុទ្ធសាស្ត្រនិងការទាមទាររបស់ IUF៖

- ការការពារផ្នែកសេដ្ឋកិច្ច
- វិធានការសុខភាពនិងសុវត្ថិភាព និង
- ការទាមទារទៅលើស្ថាប័នអន្តរជាតិ.

ការទាមទារទាំងនេះ គឺសម្រាប់កម្មករទាំងអស់គ្នា ទោះបីជាពួកគេធ្វើការនៅក្នុងក្រុមហ៊ុនអន្តរជាតិធំៗ ឬក្នុងសហគ្រាសតូចនិងមធ្យមក៏ដោយ ដោយមិនគិតពីទីតាំងភូមិសាស្ត្រ ពាសពេញសង្វាក់ផ្គត់ផ្គង់ទាំងមូល។

រាល់វិធានការនិងការទាមទារទាំងអស់ ត្រូវតែផ្តោតគោលដៅទៅរកនិរន្តរភាព ការអភិរក្សបរិស្ថាន និងការការពារសុវត្ថិភាពធនធានធម្មជាតិ។

## ផ្នែកសេដ្ឋកិច្ច

- ○ ចរចាជាមួយសហជីព ដើម្បីធានាថា កម្មកររក្សាបាននូវប្រាក់ចំណូលនិងការការពារទៅលើការងាររបស់ពួកគេ

- ផ្ដល់ការថែទាំសុខភាពសម្រាប់កម្មករទាំងអស់ ជាពិសេស នៅកន្លែងដែលមិនទាន់មានការធានាជាលក្ខណៈសាកល ទៅលើប្រព័ន្ធថែទាំសុខភាពគ្រប់គ្រាន់នៅឡើយ
- ផ្ដល់ការឈប់សម្រាកពេលឈឺដោយមានប្រាក់កម្រៃ ដែលគិតបញ្ចូលទាំងសម្រាប់ការធ្វើចត្តាឡីស័ក និងការថែទាំសាច់ញាតិដែលឈឺ
- ធានាថាគោលនយោបាយទាំងអស់ មានការគិតគូរដល់យេនឌ័រ ដោយរាប់បញ្ចូលទាំងគោលនយោបាយស្ដីពីការឈប់សម្រាកដោយមានប្រាក់កម្រៃនិងការការពារប្រាក់ចំណូល។
- ធានាថារាល់កម្មករទាំងអស់ ដោយរាប់បញ្ចូលទាំង កម្មករធ្វើការក្នុងទម្រង់ការងារមិនស្ដង់ដារ ដូចជាកម្មករមិនពេញម៉ោង កម្មករយកពីខាងក្រៅ កម្មករមានកិច្ចសន្យាគ្មានចំនួនម៉ោង និងកម្មករក្រៅប្រព័ន្ធ ទទួលបានប្រយោជន៍ពីការការពារផ្នែកសេដ្ឋកិច្ច។
- ចរចាជាមួយសហជីពនិងអនុវត្តកម្មវិធីបណ្ដុះបណ្ដាលនានា ដើម្បីរក្សាកម្មករសម្រាប់ជំនាញថ្មីៗ និងវិជ្ជាជីវៈផ្សេងៗទៀត។
- ចរចាភាសាពាក្យពេចន៍ក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួម ដែលតម្រូវឲ្យមានការចរចាជាមួយសហជីព មុននឹងអនុវត្តបច្ចេកវិទ្យានិងប្រព័ន្ធស្វ័យប្រវត្តិថ្មីណាមួយ ដែលអាចមានសក្ដានុពលប៉ះពាល់ដល់ការងារ។

## សុខភាព និងសុវត្ថិភាព

- បញ្ឈប់កម្មវិធី គោលនយោបាយ និងនីតិវិធីអនុវត្តនានា ដែលផ្លាស់ប្ដូរការទទួលខុសត្រូវ ទៅលើសុខភាពនិងសុវត្ថិភាពរបស់កម្មករ ដោយផ្ដោតទៅលើអាកប្បកិរិយារបស់កម្មករ ដែលគេអាចហៅបានថា កម្មវិធីសុវត្ថិភាពផ្អែកលើអាកប្បកិរិយា ជំនួសឲ្យគ្រោះថ្នាក់កន្លែងការងារនោះ។
- ដាក់អាណត្តិការងារដល់គណៈកម្មការសុខភាពនិងសុវត្ថិភាព **ដោយមានតំណាងសហជីព** ក្នុងការកំណត់និងវាយតម្លៃ ហានិភ័យក្នុងការប្រឈមមុខនឹងជំងឺកូវីដ-១៩ និងវិធានការក្នុងការកាត់បន្ថយ ដែលមាននីតិវិធីលម្អិតជាលាយលក្ខណ៍អក្សរ សម្រាប់ការអនុវត្តការណែនាំទាំងអស់ ដែលអាចរកបានជាភាសារបស់កម្មករ។
- **ធានាឲ្យមានការដាក់បញ្ចូលស្ត្រីទៅក្នុងគណៈកម្មការសុខភាពនិងសុវត្ថិភាព**
- ចរចាភាសាពាក្យពេចន៍នៅក្នុងកិច្ចព្រមព្រៀងអនុសញ្ញារួម ដែលផ្អែកទៅលើអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ១៩០ និងអនុសាសន៍២០៦ ដែលការពារកម្មករឲ្យជៀសផុតពីការបៀតបៀនផ្លូវភេទ។
- ដាក់អាណត្តិការងារបណ្ដុះបណ្ដាលផ្នែកសុខភាពនិងសុវត្ថិភាព និងនីតិវិធីអនុវត្តចំពោះសម្ភារៈការពារខ្លួន
- **ផ្ដល់សម្ភារៈការពារខ្លួនដោយមិនគិតថ្លៃ ក្នុងបរិមាណគ្រប់គ្រាន់ និងសមស្របទៅតាមខ្លួនប្រាណទាំងរបស់បុរសនិងស្ត្រី**
- ណែនាំអនុវត្តវិធានការការពារបន្ថែមសម្រាប់កម្មករស្ត្រីមានផ្ទៃពោះ និងសម្រាប់ស្ត្រីដែលអស់រដូវ ជាពិសេសស្ត្រីដែលមានបទពិសោធន៍មានរោគសញ្ញាឈឺចាប់
- ចរចាជាមួយសហជីព មុនណែនាំអនុវត្តវិធាននិងបច្ចេកវិទ្យាថ្មីៗសម្រាប់ការងារ ដើម្បីវាយតម្លៃផលប៉ះពាល់ទៅលើសុខភាពសាធារណៈ សុវត្ថិភាព និងកម្មករ។

- អនុវត្តតាមអនុសាសន៍អង្គការសុខភាពពិភពលោកនៅក្នុង “ការពិចារណាប្រតិបត្តិការ សម្រាប់ការគ្រប់គ្រងជំងឺកូវីដ-១៩ នៅក្នុងវិស័យស្នាក់នៅ” ដែលថា រាល់កម្មវិធីបែតងទាំងអស់ ដែលមិនលើកទឹកចិត្តដល់ការសម្អាតបន្ទប់រាល់ថ្ងៃ ត្រូវពន្យារពេលដោយគ្មានកាលកំណត់។
- ដាក់បញ្ចូលជំងឺកូវីដ-១៩ ទៅក្នុងបញ្ជីជំងឺការងាររបស់អង្គការអន្តរជាតិខាងការងារ ដូចមាននៅក្នុង សេចក្តីសង្ខេបគោលនយោបាយរបស់ក្រុមប្រឹក្សាសហជីពសាកល។

## ស្ថាប័ននិងរដ្ឋាភិបាលអន្តរជាតិ

- អង្គការសុខភាពពិភពលោក/អង្គការអន្តរជាតិខាងការងារ/អង្គការទេសចរណ៍ពិភពលោក ត្រូវអញ្ជើញ IUF ឲ្យចូលរួមនៅក្នុងគណៈកម្មការវិបត្តិទេសចរណ៍សាកលលោក ដែលបង្កើតឡើងសម្រាប់រៀបចំបង្កើតសេចក្តីណែនាំអន្តរជាតិជារួមនានា សម្រាប់វិស័យសណ្ឋាគារ ភោជនីយដ្ឋាន ទេសចរណ៍ និងម្ហូបអាហារ។
- ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដោយរួមបញ្ចូលទាំងកិច្ចសហការហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក ត្រូវផ្តល់ការសង្គ្រោះបន្ទាន់ទៅលើប្រាក់ចំណូលក្នុងគ្រាអាសន្ន ក្នុងទម្រង់ជាប្រាក់ឈ្នួល ការថែទាំសុខភាព និងការសម្រាកពេលឈឺមានកម្រៃសម្រាប់កម្មករ។
- អង្គការសហប្រជាជាតិ ត្រូវអំពាវនាវដល់រដ្ឋាភិបាល ក្នុងការអនុវត្តឧទាហរណ៍របស់ប្រទេសនានាដូចជាប្រទេសដាណឺម៉ាក ដែលជំនួយរបស់រដ្ឋាភិបាលទៅដល់អាជីវកម្មនានា មានដាក់លក្ខខណ្ឌទៅលើការពន្យារពេលនៃការចែកប្រាក់ភាគលាភរបស់ម្ចាស់ភាគហ៊ុន ការទិញហ៊ុនត្រឡប់វិញ និងការប្រើប្រាស់អត្ថប្រយោជន៍ពន្ធក្រៅប្រទេស ក៏ដូចជាក្នុងការវិនិយោគទៅលើការកសាងឡើងវិញនូវសេវាកម្មសាធារណៈ ដោយរួមបញ្ចូលទាំងការថែទាំសុខភាពសាធារណៈ។
- រដ្ឋាភិបាលត្រូវតែផ្តល់សច្ចាប័នអនុសញ្ញាអង្គការអន្តរជាតិខាងការងារលេខ ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សានិងការបៀតបៀននៅក្នុងពិភពការងារ។
- រដ្ឋាភិបាលត្រូវតែដាក់បញ្ញត្តិទៅលើកម្មករចំណាកស្រុកដែលមិនមានឯកសារគ្រប់គ្រាន់ទាំងអស់ ក្នុងការធានាឲ្យមានការទទួលបាន**ការគាំពារសង្គម រួមទាំង** ការថែទាំសុខភាពដែរ។

## ធនធានបន្ថែម៖

ការទាមទាររបស់ IUF ក្នុងពេលវិបត្តិកូវីដ-១៩៖ សណ្ឋាគារ

ការទាមទាររបស់ IUF ក្នុងពេលវិបត្តិកូវីដ-១៩៖ អាហាររហ័ស (Fast Food)

ការទាមទាររបស់ IUF ក្នុងពេលវិបត្តិកូវីដ-១៩៖ សមភាព